## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជានៅទីរួមខេត្តតាកែវ
## ថ្ងៃទី១៥ សីហា ២០១៧

អត្ថបទទី១៖វវ ១១,១៩ក.១២,១-៦ក.១០កខ
អត្ថបទទី២៖១ករ ១៥,២០-២៧ក
ដំណឹងល្អ៖លក ១,៣៩-៥៦

បងប្អូនជាទីស្រឡាញ់!

លោកឪពុកហ៊ិន គាត់បានចាប់ផ្ដើមបង្កើតព្រះសហគមន៍កម្ពុជានៅក្រចេះ គាត់ជួលផ្ទះមួយនៅម្នាក់ឯង ក្រោយមកមានបងប្អូនខ្លះៗដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក។ ក្រោយមកលោកឪពុកទៅបម្រើនៅព្រះសហគមន៍មណ្ឌលគិរី ដើម្បីប្រកាសដំណឹងល្អនៅទីនោះ។ នៅទីរួមខេត្តតាកែវនេះ ក៏ជាកន្លែងដែលយើងចាប់ផ្ដើមពីសូន្យដែរ លោកឪពុកដូស្សបានជួលផ្ទះនេះនៅឆ្នាំ២០១១ ដើម្បីចាប់ផ្ដើមប្រកាសដំណឹងល្អដោយនៅទីនេះយើងមានគ្រីស្តបរិស័ទម្នាក់ ក្រោយមកយើងមានប៉ុន្មាននាក់ថែមទៀតដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក។ នៅតាកែវយើងចាប់ផ្ដើមពីចំការទៀងជាមួយលោកគ្រូជៀង ក្រោយមកនៅគិរីវង់ជាមួយលោកតាចយ និងលោកតាសុខ ក្រោយមកនៅព្រៃកប្បាស់ជាមួយលោកគ្រូធា ក្រោយមកនៅទីរួមខេត្តតាកែវជាមួយពូនីល ក្រោយមកនៅសន្តប៉ូលជាមួយលោកតាបូរ ក្រោយមកនៅកំពង់អំពិល ក្រោយមកនៅទន្លេបាទី ក្រោយមកទៀតនៅត្រពាំងក្រញូង។ នេះជារបៀបដែលយើងចាប់ផ្ដើមព្រះសហគមន៍ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់។ ព្រះជាម្ចាស់ណែនាំឲ្យយើងធ្វើចំការទំពាំងបាជូរ ចំការរបស់យើងគឺកន្លែងដែលយើងមានជីវិតជាសាសនាទូត គឺយើងត្រូវតែខិតខំចូលនៅក្នុងវប្បធម៌ថ្មី ដើម្បីឲ្យគេទទួលស្គាល់យើង ដោយដឹងថាគ្រប់ឧបសគ្គដែលយើងជួប មិនសំខាន់ទេព្រោះយើងមានព្រះយេស៊ូគង់នៅជាមួយយើង ដើម្បីធ្វើដំណើរជាមួយយើង ដើម្បីបន្តឲ្យមានផ្លែ។

សាសនាទូត យើងមិននៅកន្លែងណាមួយរហូតទេ យើងត្រូវការចេញពីកន្លែងមួយទៅកន្លែងមួយ នៅប្រទេសកម្ពុជាយើងមានលោកបូជាចារ្យ និងបងស្រីចេញពីទឹកដីកម្ពុជាតិចណាស់ ដូច្នេះប្រសិនបើសាសនាទូតចេះតែចេញទៅវិញ ធ្វើឲ្យគ្រីស្តបរិស័ទខ្វះគ្រូគង្វាល។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវតែទទួលស្វាគមន៍លោកបូជាចារ្យដែលមកពីប្រទេសផ្សេងៗ និងជាពិសេសមកពីខ្មែរ។ លោកបូជាចារ្យដែលមកពីបរទេសគាត់មានវប្បធម៌ផ្សេងពីខ្មែរ ដូច្នេះគ្រីស្តបរិស័ទយើងដែលនៅទីនេះត្រូវតែទទួលស្វាគមន៍

លោក ដែលមកដើម្បីប្រកាសដំណឹងល្អដោយនាមព្រះយេស៊ូ។ លោកបូជាចារ្យក៏ត្រូវមានការសហការជាមួយគ្រីស្តបរិស័ទនៅតាមកន្លែងនីមួយៗ ដើម្បីឲ្យយើងអាចប្រមូលបងប្អូនកុមារ យុវជន ចាស់ៗ ដើម្បីបង្កើតមហាគ្រួសារមួយ។ ដូច្នេះលោកបូជាចារ្យត្រូវតែសហការជាមួយគ្រីស្តបរិស័ទនៅតាមកន្លែងនីមួយៗ ដើម្បីឲ្យព្រះសហគមន៍របស់យើងមានជីវិតដោយមានទំនាក់ទំនងជាមួយបងប្អូនឯទៀតៗតាមភូមិដែលយើងនៅ ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាកន្លែងមួយដែលប្រមូលមនុស្សពីគ្រប់ទីកន្លែង។ យើងអាចធ្វើបានលុះត្រាតែលោកបូជាចារ្យសហការជាមួយបងប្អូននៅតាមកន្លែងនីមួយៗ ដើម្បីបង្ហាញធម៌មេត្តាករុណាដែលយើងបានទទួលពីព្រះជាម្ចាស់។

សូមអរគុណលោកឪពុក ហ៊ាន ដែលបានជួយព្រះសហគមន៍នៅប្រទេសកម្ពុជាអស់រយៈពេល២០ឆ្នាំកន្លងមក ដើម្បីប្រកាសដំណឹងល្អ។ សូមអរគុណលោកឪពុកទាំងអស់ដែលបានជួយព្រះសហគមន៍នៅប្រទេសកម្ពុជា សូមអរព្រះគុណព្រះជាម្ចាស់ដែលបានណែនាំឲ្យយើងអាចប្រកាសដំណឹងល្អរួមជាមួយគ្នា ដើម្បីកសាងមហាគ្រួសារនៅក្នុងអង្គព្រះគ្រីស្ត។ សម្រាប់គ្រីស្តបរិស័ទយើងត្រូវតែចាប់អារម្មណ៍ជាមួយអ្នកជំងឺដែលគ្មានអ្នកយកចិត្តទុកដាក់ ជាមួយអ្នកក្រីក្រ ដើម្បីឲ្យព្រះសហគមន៍របស់យើងអាចចូលនៅក្នុងជីវិតសាមញ្ញធម្មតារបស់បងប្អូន ដោយបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ថ្ងៃនេះជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍យើងសម្រាប់លោកឪពុកដែលត្រូវទៅប្រទេសកូឡុំប៊ី អាចចែកបទពិសោធយ៉ាងពិសេសអំពីជីវិតដែលព្រះយេស៊ូបានប្រទានដល់បងប្អូននៅប្រទេសកម្ពុជា។ យើងនៅស្ងៀមស្ងាត់ ទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើយើងថែមទៀត ឲ្យយើងទៅប្រកាសដំណឹងល្អកុំឲ្យយើងអស់កម្លាំង កុំឲ្យយើងអស់សង្ឃឹម ឲ្យយើងដឹងថាពិតមែនព្រះយេស៊ូគង់នៅជាមួយយើងរហូតដល់ថ្ងៃចុងក្រោយបំផុតនៃជីវិតយើង។ អាម៉ែន៕